ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ

សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៨
ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨
សាលក្រមព្រហ្មទណ្ឌលេខ ៧១ "ឈ"
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបើកសវនាការជាសាធារណៈនា ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០
វេលាម៉ោង ៩:០០ នាទីព្រឹក ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុជាតិ ភេទស្រី អាយុ៣៨ឆ្នាំ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ស្ពឺ មុខរបរកសិករ ឪពុកឈ្មោះ [redacted] ឈឿន (រ) ម្តាយឈ្មោះ [redacted] ភឹមនី (រ) ប្តីឈ្មោះ [redacted] សុយនណាវី (រ) មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ **ហិង្សាដោយចេតនា ជេរប្រមាថជាសាធារណៈ និងអំពើផិត** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២១៧, ៣០៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧, ១០ នៃច្បាប់ស្តីពីឯកពន្ធភាព។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុយនណាវី ហៅ ល ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរពលករនៅប្រទេសកូរ៉េ ទីលំនៅបច្ចុប្បន្ន ភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**អង្គហេតុដែលបានចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះ**

កាលពីខែមករា ឆ្នាំ២០១៧ មានករណីហិង្សាដោយចេតនា ជេរប្រមាថជាសាធារណៈ និងអំពើផិតកើតឡើង បង្កដោយឈ្មោះ [redacted] សុជាតិ ភេទស្រី អាយុ៣៨ឆ្នាំ រស់នៅភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយឈ្មោះ [redacted] សុជាតិ បានប្រើហិង្សាក្នុងគ្រួសារវាយទៅលើកូនខ្លួនឯងឈ្មោះ [redacted] ណារិនដារ៉ូ ភេទប្រុស អាយុ១៦ឆ្នាំ ព្រមទាំងបណ្តេញចេញពីផ្ទះ និងតែងតែជេរប្រមាថទៅលើឈ្មោះ [redacted] ណំ ភេទស្រី អាយុ

៦០ឆ្នាំ ដែលត្រូវជាម្ដាយ អ៊ុំ និងបានផិតក្បត់ ដោយយកមនុស្សប្រុសមករស់នៅជាលក្ខណៈប្ដីប្រពន្ធនៅផ្ទះរបស់ខ្លួន ខណៈប្ដីខ្លួនឈ្មោះ [redacted] សុយនណាវី ទៅធ្វើការជាពលករនៅប្រទេសកូរ៉េ។ ក្រោយកើតហេតុជនរងគ្រោះបានមកដាក់ពាក្យបណ្ដឹងដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍សំយោកលេខៈ ៣៧/១៩ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨ របស់ស្នងការដ្ឋាននគរបាលខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៣០៧ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦១៣៨ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៥៦៦ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ស្ពឺ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានឆ្លើយនៅពេលសវនាការថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយខ្លួនមិនបានប្រើអំពើហិង្សាលើកូនឈ្មោះ [redacted] ណារិនដារ៉ូ ផិតក្បត់ និងជេរប្រមាថទៅលើអ៊ុំស្រីនោះទេ។ ខ្លួនសូមបញ្ជាក់ថា កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០១៧ ពេលដែលអតីតប្ដីរបស់ខ្លួនឈ្មោះ [redacted] សុយនណាវី ត្រឡប់មកពីធ្វើការនៅកូរ៉េ កូនរបស់ខ្លួនឈ្មោះ [redacted] ណារិនដារ៉ូ មិនព្រមទៅរៀន ហើយដើរលេងជាមួយឪពុកគេរហូតដល់ម៉ោង ១១ ទៅ ១២យប់។ លុះថ្ងៃមួយខ្លួនក៏បានសួរកូនខ្លួនថា ម៉េចមិនទៅរៀន? វាមិនឆ្លើយខ្លួនក៏បានច្របាច់មាត់របស់វា ហើយវាងាកក្បាលចេញ បណ្ដាលឲ្យប៉ះក្រចករលាត់ក្រោមថ្ពាល់បន្តិច។ បន្ទាប់មកអតីតប្ដីរបស់ខ្លួនក៏បាននាំកូនទៅដាក់ពាក្យបណ្ដឹង តែមេភូមិ និងសមត្ថកិច្ចមិនទទួលពាក្យបណ្ដឹង។ ហើយខ្លួនក៏មិនដែលបណ្ដេញកូនខ្លួនចេញពីផ្ទះដែរ។ ចំពោះទាក់ទងនឹងការចោទប្រកាន់ថា ខ្លួនបានជេរប្រមាថលើអ៊ុំស្រីឈ្មោះ [redacted] ណំ គឺមិនពិតដែរ ខ្លួនមិនដែលជេរប្រមាថលើគាត់ទេ តែគាត់ធ្លាប់ជេរប្រមាថមកលើខ្លួនម្ដង ដោយគាត់ធ្លាប់ជេរខ្លួនថា មីសំផឹង តែខ្លួនមិនបានតបតនោះទេ គ្រាន់តែសួរថា ហេតុអីបានជេរខ្លួន។ ហើយឈ្មោះ [redacted] ណំ ជេរខ្លួនពេលនោះ ក៏ដោយសារតែជឿពាក្យសម្ដីអតីតប្ដីរបស់ខ្លួន។ ចំពោះការផិតក្បត់ គឺខ្លួនមិនបានប្រព្រឹត្តនោះទេ គ្រាន់តែធ្លាប់មានបងប្រុសឈ្មោះ សិទ្ធិ មកពីក្រៅប្រទេសមកលេង និងស្នាក់នៅផ្ទះចំនួន ០១សប្ដាហ៍ តែពេលនោះខ្លួនពុំមានទំនាក់ទំនងអ្វីនឹងគ្នានោះទេ។ ហើយខ្លួន និងអតីតប្ដីរបស់ខ្លួនពុំមានសំបុត្រអាពាហ៍ពិពាហ៍នោះទេ។

-សាក្សីឈ្មោះ [redacted] ណំ បានឆ្លើយនៅពេលសវនាការថា៖ ខ្លួនធ្លាប់ជេរឈ្មោះ [redacted] សុជាតិ ពិតមែន ដោយសារតែខឹងឈ្មោះ [redacted] សុជាតិ តែងតែឈ្លោះគ្នាជាមួយប្ដីរបស់គេ។ ហើយខ្លួនធ្លាប់ឈ្លោះគ្នា ដោយពាក្យសម្ដីជាមួយឈ្មោះ [redacted] សុជាតិ តែគេមិនដែលជេរខ្លួនទេ។ ហើយឈ្មោះ [redacted] សុជាតិ មិនដែលវាយឈ្មោះ [redacted] ណារិន ហៅ រ៉ូ នឹងខ្សែក្រវ៉ាត់នោះទេ គ្រាន់តែស្ដីប្រដៅធម្មតា។

-សាក្សីឈ្មោះ [redacted] ជាខ្សែន បានឆ្លើយនៅពេលសវនាការថា៖ ពេលឪពុករបស់ខ្លួនមិននៅ គឺបងប្រុសរបស់ខ្លួនឈ្មោះ [redacted] ណារិន ហៅ រ៉ូ តែងតែឈ្លោះជាមួយម្ដាយរបស់ខ្លួន និងចង់កាប់ម្ដាយរបស់ខ្លួនទៀត។ ហើយម្ដាយខ្លួនមិនដែលវាយបងប្រុសឈ្មោះ [redacted] ណារិន ដារ៉ូ នោះទេ។ ឈ្មោះ [redacted] ណំ និងម្ដាយរបស់ខ្លួន នៅផ្ទះ

ជាមួយគ្នា តែមិនដឹងថា ធ្លាប់ឈ្លោះគ្នា ឬអត់នោះទេ។ ពេលប៉ាមិននៅ ម៉ាក់បាននាំអ៊ុំសិទ្ធិ មកលេងនៅផ្ទះមួយខែ។ គាត់គេជិតបន្ទប់របស់ខ្លួន។ ហើយអ៊ុំក្លាមក៏ធ្លាប់មកលេងផ្ទះដែរ។

-សាក្សីឈ្មោះ [redacted] ភីមនី បានឆ្លើយនៅពេលសវនាការថា៖ ខ្លួនជាម្ដាយបង្កើតរបស់ឈ្មោះ [redacted] សុជាតិ។ កូនខ្លួនមិនដែលវាយចៅឈ្មោះ [redacted] ណារិន ហៅ រ៉ូ នោះទេ។ ពេលកូនប្រសារមកពីកូរ៉េក៏ឈ្លោះគ្នា ដោយសារកូនខ្លួនដេញកូនឈ្មោះ [redacted] ណារិន ទៅរៀន តែគេមិនឆ្លើយ ហើយកូនស្រីរបស់ខ្លួនក៏ច្របាច់មាត់ រួចក៏រលាត់បន្តិច ហើយកូនប្រសារបានទៅដាក់ពាក្យបណ្ដឹង តែប៉ូលីសមិនព្រមទទួល។ ពេលកូនប្រសារមកពីកូរ៉េ ខ្លួនក៏រស់នៅក្នុងផ្ទះនោះដែរ។

-ក្រឡាបញ្ជីអានពាក្យបណ្ដឹងរបស់មេធាវី [redacted] នៅពេលសវនាការថា៖ កូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី កើតទុកមិនសុខចិត្តនឹងឈ្មោះ [redacted] សុជាតិ ត្បិតចាប់តាំងពីឆ្នាំ២០១៥ ក្រោយពេលដែលកូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី ទៅធ្វើពលករនៅប្រទេសកូរ៉េ ឈ្មោះ [redacted] សុជាតិ ត្រូវជាប្រពន្ធបានលួចលាក់មានប្រុសថ្មី រហូតនាំប្រុសថ្មីឈ្មោះ សិទ្ធិ មករស់នៅក្នុងផ្ទះ និងរួមសេវនកិច្ចនៅលើគ្រែក្នុងផ្ទះរបស់កូនក្ដីខ្លួនដែលត្រូវជាប្ដី ពេលច្បាប់ដោយបើកចំហមិនខ្លាចក្រែងសាច់ញាតិខាងប្ដី និងមិនខ្មាស់អៀនអ្នកស្រុកភូមិទេ។ អំពើផិតក្បត់របស់ឈ្មោះ [redacted] សុជាតិ ក៏បានដឹងដល់ឈ្មោះ [redacted] សៀប ត្រូវជាម្ដាយក្មេក ឈ្មោះ [redacted] ណារិន ហៅ រ៉ូ ត្រូវជាកូន និងដឹងដល់បងប្អូនទាំងអស់ នៅពេលបានដឹងរឿងផិតក្បត់នេះ ម្ដាយក្មេក កូន និងបងប្អូនទាំងអស់បានខិតខំប្រឹងប្រែងព្យាយាមពន្យល់ណែនាំ អូសទាញឈ្មោះ [redacted] សុជាតិ យ៉ាងណាក៏ដោយ ក៏ឈ្មោះ [redacted] សុជាតិ ត្រូវជាប្រពន្ធរបស់កូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី មិនព្រមបញ្ឈប់អំពើផិតរបស់ខ្លួនដែរ មិនតែប៉ុណ្ណោះនៅពេលកូនក្ដីខ្លួនឈ្មោ[redacted] សុយនណារី ត្រូវជាប្ដីចេញពីប្រទេសកូរ៉េមកលេងផ្ទះនៅប្រទេសកម្ពុជាម្ដងៗប្រពន្ធឈ្មោះ [redacted] សុជាតិ តែងតែជេរប្រមាថបោះសំលៀកបំពាក់បណ្ដេញប្ដីដែលជាកូនក្ដីខ្លួនចេញពីផ្ទះ ហើយក្នុងពេលដែលកំពុងផិតក្បត់នេះ ឈ្មោះ [redacted] សុជាតិ បានដុតរូបថតកូនក្ដីខ្លួន និងរូបថតរៀបការជាមួយគ្នាចោល បានរុះរើរោងគោ ដែលកូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី ធ្លាប់តម្កល់ធ្យូងកាលពីនៅរកស៊ីបើករ៉ឺម៉កដឹកធ្យូងចោល ព្រមទាំងនង្គ័ល រនាស់របស់កូនក្ដីខ្លួន ខ្លួនឈ្មោះ [redacted] សុយនណារី ធ្លាប់ប្រើប្រាស់បង្កបង្កើនផលក៏ប្រពន្ធឈ្មោះ [redacted] សុជាតិ ប្រគល់ទៅឲ្យគេអស់ដែរ សូម្បីតែប្រាក់ដែលកូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី ផ្ញើមកប្រទេសកូរ៉េរាប់ម៉ឺនដុល្លារក៏គ្មាននៅសេសសល់ដែរ ហើយចាប់ពីឈ្មោះ [redacted] សុជាតិ ជាប្រពន្ធកូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី មានប្រុសថ្មីមក នៅពេលដែលដឹងថា កូនៗឈ្មោះ [redacted] ណារិន ហៅ រ៉ូ ភេទប្រុស អាយុ១៦ឆ្នាំ ឈ្មោះ [redacted] ជាឡែន ភេទប្រុស អាយុ១០ឆ្នាំ និងកូនឈ្មោះ [redacted] នីហ្សា ហៅ អាជី ភេទស្រី អាយុ០៦ឆ្នាំ មានទំនាក់ទំនងជាមួយកូនក្ដីខ្លួនឈ្មោះ [redacted] សុយនណារី ដែលត្រូវជាឪពុក និងមានទំនាក់ទំនងខាងក្រុមគ្រួសាររបស់ឪពុកឈ្មោះ [redacted] សុជាតិ ដែលត្រូវជាម្ដាយតែងតែប្រើហិង្សាដោយបិទទ្វាយវាយកូនៗនៅក្នុងផ្ទះ និងប្រើហិង្សាវាយធ្វើបាបកូនៗជាញឹកញាប់ដោយវាយនឹងខ្សែភ្លើង វាយនឹងខ្សែក្រវ៉ាត់ វាយនឹងមែកឈើ។ ក្រៅពីអំពើផិតក្បត់ បំផ្លិចបំផ្លាញ និងប្រើហិង្សាទៅលើកូនៗដែលជាអនីតិជន ឈ្មោះ [redacted] សុជាតិ បានប្រមាថមើលងាយដល់ម្ដាយក្មេកឈ្មោះ [redacted] សៀប ថា អញស្អប់មីកញ្ជាស់សៀប ជាងគេ ជេរប្រមាថ មើលងាយប្ដីថា អា ល អាងាប់ធ្លាក់យន្តហោះគ្មានសល់កំទេច អ្វែងល្មមដោះលែងអញទៅ ហ្វែងនៅចងពារអញដល់ណាទៀត អាចុយម្រាយ កណ្ដុយម៉ែវា អញធ្វើអញ្ចឹងអ្វែង ធ្វើអីអញ ទោះបីពូអ្វែងធ្វើមេធាវី វាធ្វើអីអញកើត មិនតែប៉ុណ្ណោះនៅពេលដែលឈ្មោះ [redacted] ណំ ត្រូវជាអ៊ុំណែនាំថា កុំរុះរើរោងគោ



Scanned with CamScanner

នឹងធ្វើអី ព្រោះជារោងគោរបស់ អា ល ទេ ពេលនោះស្រាប់តែឈ្មោះ [redacted] សុជាតិ បានស្ទុះមកទះកំភ្លាង និងច្របាច់ករអ៊ុំ [redacted] ណំា និងថែមទាំងនិយាយថា អ៊ុំឯងខ្ញុំចាត់ទុកដូចសំរាម ខ្ញុំបោះចោលថ្ងៃណាក៏បានដែរ ប្រហែល អា ល វាចិញ្ចឹមខ្ញុំអស់រាប់ម៉ឺនដុល្លារផងខ្ញុំបោះចោលបាន។ ហើយនៅពេលថ្មីៗនេះ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៨ ប្រហែលម៉ោង ៧យប់ ឈ្មោះ [redacted] សុជាតិ បានវាយធ្វើបានកូនឈ្មោះ [redacted] ជាខ្សែន ដោយចាប់ហែកមាត់មូលឡើងជាំ។ ចំពោះអំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] សុជាតិ ដូចខាងលើនេះ មានសាក្សីឈ្មោះ [redacted] សាវ៉ាត ភេទប្រុស អាយុ៦៥ឆ្នាំ ជាមេភូមិឡ មានទីលំនៅ ភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងឈ្មោះ [redacted] ហៃ ភេទស្រី អាយុ៥៨ឆ្នាំ ជាប្រជាពលរដ្ឋ មានទីលំនៅ ភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ជាអ្នកដឹងឮ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារិន នៅពេលសវនាការថា៖ ខ្លួនជាកូនរបស់ដើមបណ្តឹង និងជនត្រូវចោទ ខ្លួនសូមបញ្ជាក់ថា ឪពុករបស់ខ្លួនទៅធ្វើការនៅកូរ៉េតាំងពីឆ្នាំ២០១៥ ហើយចាប់ពីឪពុកខ្លួនទៅធ្វើការ ម្តាយរបស់ខ្លួនតែងតែវាយខ្លួន និងប្អូន គឺនៅពេលគាត់ឈ្លោះគ្នាជាមួយប៉ារបស់ខ្លួនតាមទូរស័ព្ទ ហើយនៅឆ្នាំ២០១៧ ខែកុម្ភៈ ប៉ារបស់ខ្លួនបានមកលេងខ្មែរ ចំនួន ០២ខែហើយ ពេលមកផ្ទះ គាត់សួរនាំរឿងលុយ ដែលគាត់ផ្ញើរមក តែម្តាយខ្លួនឈ្លោះ និងជេរឪពុកខ្លួន ហើយថែមទាំងវាយខ្លួន និងប្អូនខ្លួនទៀត ដោយយកខ្សែក្រវ៉ាត់ វ៉ាពត់ និងខ្សែភ្លើងវាយ លុះក្រោយពេលឪពុកខ្លួនទៅកូរ៉េវិញ ម្តាយខ្លួនបានទាក់ទងជាមួយអាណិកជនម្នាក់នៅបារាំងតាមទូរស័ព្ទ លុះនៅអំឡុងខែកុម្ភៈ និង មីនា អាណិកជននៅបារាំងនោះ មកលេងស្រុកខ្មែរ ហើយបាននាំគ្នាជាមួយម្តាយខ្លួនទៅលេងសមុទ្រតែពីរនាក់ ប្រហែលបួន ដប់ថ្ងៃ បានមកផ្ទះវិញ ហើយថែមទាំងនាំប្រុសនោះមកនៅផ្ទះជាមួយគ្នាប្រហែលកន្លះខែ បានគេត្រឡប់ទៅវិញ។ ហើយកាលប្រុសនោះមកនៅផ្ទះ ខ្លួនគេដេកលើផ្ទះជាមួយម្តាយខ្លួន ឯរូបខ្លួនដេកនៅក្រោមផ្ទះ ហើយម្តាយខ្លួនតែងតែវាយខ្លួន ហើយថាកុំឲ្យចេះដឹងរឿងគាត់។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភា នៅពេលសវនាការថា៖ ចំពោះរឿងនេះ ខ្លួនមិនបានដឹងអ្វីទេ ព្រោះខ្លួននៅផ្ទះឆ្ងាយពីផ្ទះរបស់ឈ្មោះ [redacted] សុជាតិ ហើយគ្រាន់តែដឹងថាប្តីគាត់ទៅប្រទេសកូរ៉េនៅអំឡុងឆ្នាំ២០១៤ ក្រោយមកខ្លួនមិនបានដឹងទេ ហើយក៏មិនដឹងថាប្តីមកខ្មែរលេង ឬអត់ទេ។ ចំពោះរឿងជេរប្រមាថប្តី ក៏ខ្លួនមិនដឹង រឿងប្រើអំពើហិង្សាចំពោះកូន និងរឿងផិតប្តីក៏ខ្លួនមិនដឹងដែរ គ្រាន់តែកាលអំឡុងខែមីនា ឆ្នាំ២០១៨ ឈ្មោះ សុជាតិ បានឲ្យខ្លួនទៅរុះយករោងគោគាត់ទៅ ព្រោះគាត់ត្រូវដីដាំដំណាំ ហើយគ្មានគោចិញ្ចឹមផង និងលឺឈ្មោះ ស៊ូ សុជាតិ បានជជែកគ្នាជាមួយអ៊ុំស្រីរបស់គាត់ឈ្មោះ ណំ តែមិនដឹងជជែករឿងអ្វីទេ។ ចំពោះរឿងនេះ ខ្លួនដឹងតែប៉ុណ្ណឹងទេ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីនាង នៅពេលសវនាការថា៖ ខ្លួនសុំឆ្លើយតែការពិតនូវរឿងហេតុដែលខ្លួនបានដឹងបានឃើញ និងបានចាំផ្ទាល់។ ខ្លួន និងឈ្មោះ [redacted] សុជាតិ គឺជាអ្នកភូមិជាមួយគ្នាហើយ ផ្ទះខ្លួនគឺនៅរំលង ១០ផ្ទះបានដល់ផ្ទះ [redacted] សុជាតិ ចំពោះរឿងហេតុដែលឲ្យខ្លួនមកធ្វើសាក្សី គឺខ្លួនមិនបានដឹងអ្វីទេ ព្រោះផ្ទះគាត់ ហើយខ្លួនគ្រាន់តែដឹងថា ប្តីគាត់ទៅធ្វើការនៅប្រទេសកូរ៉េ ហើយធ្លាប់មកលេងផ្ទះម្តង ហើយលឺគេថា គាត់ឈ្លោះគ្នាប្តីប្រពន្ធពេលគាត់មកលេង។ ចំពោះប្រុសក្នុងរូបថតដែលបង្ហាញខ្លួននេះ ខ្លួនមិន



Scanned with CamScanner

ដែលស្គាល់ទេ ព្រោះមិនមែនអ្នកភូមិខ្លួន តែខ្លួនធ្លាប់ឃើញម្តង មិនចាំថ្ងៃណាទេ គឺធ្លាប់ដើរកាត់មុខផ្ទះខ្លួន។ ចំពោះរឿងនេះខ្លួនដឹងតែប៉ុណ្ណឹង។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] សៀ នៅពេលសវនាការថា៖ ខ្លួនសូមឆ្លើយតែការពិតនូវរឿងហេតុដែលខ្លួនបានដឹងបានឃើញបានលឺ និងបានចាំផ្ទាល់។ ចំពោះរឿងហេតុដែលឲ្យខ្លួនមកធ្វើសាក្សី គឺខ្លួនមិនបានដឹងទេ ព្រោះផ្ទះរបស់ខ្លួននៅឆ្ងាយរំលង ៧ផ្ទះពីផ្ទះរបស់ឈ្មោះ [redacted] សុជាតិ ខ្លួនគ្រាន់តែដឹងថាប្តីរបស់គាត់ទៅធ្វើការនៅប្រទេសកូរ៉េប្រហែល ៣ ទៅ ៤ខែហើយ ហើយធ្លាប់មកលេងខ្មែរម្តង ហើយកាលនោះលឺថា មានទំនាស់គ្នាប្តីប្រពន្ធគាត់ តែខ្លួនមិនបានឃើញហេតុការណ៍ទេ ហើយក៏មិនដឹងទំនាស់គ្នារឿងអ្វីដែរ។ ចំពោះរឿងប្រើហិង្សាចំពោះកូនក៏ខ្លួនមិនដែលឃើញ មិនដែលដឹងទេ។ ចំពោះរឿងថា ឈ្មោះ [redacted] សុជាតិ មានប្រុស ខ្លួនក៏មិនដឹងដែរ ព្រោះផ្ទះឆ្ងាយពីគ្នា ហើយចំពោះរូបប្រុសដែលបង្ហាញមានតែជាមួយឈ្មោះ [redacted] សុជាតិ ខ្លួនមិនដែលឃើញ ហើយមិនដែលស្គាល់ទេ ចំពោះរឿងនេះ ខ្លួនដឹងតែប៉ុណ្ណឹង។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ៅ នៅពេលសវនាការថា៖ ខ្លួនសូមឆ្លើយតែការពិតនូវរឿងហេតុដែលខ្លួនបានដឹងបានឃើញបានលឺ និងបានចាំផ្ទាល់។ ខ្លួននៅភូមិជាមួយឈ្មោះ [redacted] សុជាតិ តែនៅរំលងពីផ្ទះគាត់ ៨ផ្ទះ ហើយគ្រាន់តែដឹងថា ប្តីរបស់ [redacted] សុជាតិ ទៅធ្វើការនៅប្រទេសកូរ៉េ ហើយធ្លាប់មកលេងប្តីម្តង ប្រហែល ១ ទៅ ២ខែ ហើយធ្លាប់ទៅលេងផ្ទះខ្លួន ហើយប្រាប់ខ្លួនថាជំលោះក្នុងគ្រួសារ តែមិនប្រាប់ថាឈ្លោះគ្នារឿងអ្វីទេ។ ហើយខ្លួនបានឃើញពួកគាត់ឈ្លោះគ្នាដែរ កាលនោះប្តីវាប្រាប់ថា ប្រហែលប្រពន្ធត្រូវអំពើគេ តែរឿង [redacted] សុជាតិ វាយកូនខ្លួនមិនបានដឹងទេ។ ហើយរឿងជេរប្រមាថ ក៏ខ្លួនមិនដឹងដែរ ក្រោយពេលប្តីគាត់ទៅប្រទេសកូរ៉េ ធ្លាប់ឃើញមនុស្សប្រុសម្នាក់មកលេងផ្ទះ [redacted] សុជាតិ ស្នាក់នៅប្រហែល ២ ទៅ ៣ថ្ងៃ ហើយ [redacted] សុជាតិ ប្រាប់ខ្លួនថា អ្នករាប់អានគ្នា ហើយមិនដឹងថា ពួកគាត់ដើរលេងជាមួយគ្នាទេ ចំពោះរឿងនេះ ខ្លួនដឹងតែប៉ុណ្ណឹងទេ។

-ក្រឡាបញ្ជីអានចម្លើយរបស់សាក្សីឈ្មោះ [redacted] ហៃ នៅពេលសវនាការថា៖ នៅថ្ងៃខែមិនចាំ ឈ្មោះ [redacted] ណំ បានមកប្រាប់ខ្លួនថា ឈ្មោះ [redacted] សុជាតិ ត្រូវជាក្មួយរបស់គាត់បានមកជេរប្រមាថគាត់ថាមីកញ្ជាស់ង៉ែងយកអា ល ([redacted] សុយនណារី) ទៅ ព្រោះង៉ែងធ្វើសាក្សីឲ្យវា ហើយ [redacted] ណំ និយាយទៀតថា [redacted] សុជាតិ បានគំរាមគាត់ថា មីកញ្ជាស់ឯងបានតែក្បាលមួយស្បែកជើងទេ (ប៉ុន្តែនេះជាពាក្យគំរាមទេ) ហើយឈ្មោះ [redacted] សុជាតិ ធ្លាប់បានឧបជនបរទេសម្នាក់មកលេងផ្ទះរបស់ខ្លួនដែរ។

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានសួរដេញដោលឃើញថា ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពិតជាបានឆ្លើយបដិសេធ ប៉ុន្តែតាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី បានបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦១៣៨ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ ទុកនៅដដែល ដោយចោទប្រកាន់ពីបទ៖ **ហិង្សាដោយចេតនា ជេរប្រមាថជាសាធារណៈ និងអំពើជិត** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២១៧, ៣០៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧, ១០ នៃច្បាប់ស្តីពីឯកពន្ធភាព។

**-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ភារម្យ ធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានសួរដេញដោលឃើញថា ខ្លួនសុំបដិសេធការចោទប្រកាន់ទាំងស្រុង។ ដោយសារកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការ



Scanned with CamScanner

ចោទប្រកាន់នោះទេ។ ចំពោះការប្រើអំពើហិង្សា គឺកូនក្តីរបស់ខ្លួនពុំដែលប្រើអំពើហិង្សាលើកូនឈ្មោះ [redacted] ណារិន ហៅ រ៉ូ ធ្ងន់ធ្ងរនោះទេ គឺគ្រាន់តែប្រដៅណែនាំអប់រំកូនក្នុងនាមជាម្តាយប៉ុណ្ណោះ។ រីឯការជេរប្រមាថឈ្មោះ [redacted] ណំ គឺមិនពិតនោះទេ ព្រោះសាក្សីឈ្មោះ [redacted] ណំ បានបញ្ជាក់ក្នុងសវនាការពេលនេះហើយថា កូនក្តីខ្លួនមិនបានជេរគាត់នោះទេ។ រីឯបទល្មើសផិត គឺពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដោយសារតែកូនក្តីខ្លួន និងឈ្មោះ [redacted] សុយនណារី ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នោះទេ។ ដូចនេះស្នើសុំឲ្យកូនក្តីរបស់ខ្លួនរួចផុតពីបទចោទ។

-សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ៖ សុំឲ្យតុលាការសម្រេចឲ្យខ្លួនរួចផុតពីបទចោទ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាងនិងឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់ជនជាប់ចោទសំណូមពរ និងសំដីចុងក្រោយ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ស្ពឺ
## យល់ឃើញថា

១-អង្គហេតុដែលបានបញ្ជូនមកជំនុំជម្រះគឺ កាលពីខែមករា ឆ្នាំ២០១៧ មានករណីហិង្សាដោយចេតនា ជេរប្រមាថជាសាធារណៈ និងអំពើផិតកើតឡើង បង្កដោយឈ្មោះ [redacted] សុជាតិ ភេទស្រី អាយុ៣៨ឆ្នាំ រស់នៅភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដោយឈ្មោះ [redacted] សុជាតិ បានប្រើហិង្សាក្នុងគ្រួសារវាយទៅលើកូនខ្លួនឯងឈ្មោះ [redacted] ណារិន ហៅ រ៉ូ ភេទប្រុស អាយុ១៦ឆ្នាំ ព្រមទាំងបណ្តេញចេញពីផ្ទះ និងតែងតែជេរប្រមាថទៅលើឈ្មោះ [redacted] ណំ ភេទស្រី អាយុ៦០ឆ្នាំ ដែលត្រូវជាម្តាយ អ៊ុំ និងបានផិតក្បត់ ដោយយកមនុស្សប្រុសមករស់នៅជាលក្ខណៈប្តីប្រពន្ធនៅផ្ទះរបស់ខ្លួន ខណៈប្តីខ្លួនឈ្មោះ [redacted] សុយនណារី ទៅធ្វើការជាពលករនៅប្រទេសកូរ៉េ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយខ្លួនមិនបានប្រើអំពើហិង្សាលើកូនឈ្មោះ [redacted] ណារិនជារ៉ូ ផិតក្បត់ និងជេរប្រមាថទៅលើឈ្មោះ [redacted] ណំ នោះទេ។ ដោយកាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០១៧ ពេលដែលអតីតប្តីរបស់ខ្លួនឈ្មោះ [redacted] សុយនណារី ត្រឡប់មកពីធ្វើការនៅកូរ៉េ កូនរបស់ខ្លួនឈ្មោះ [redacted] ណារិន ហៅ រ៉ូ មិនព្រមទៅរៀន ហើយខ្លួនក៏បានសួរនាំ តែគេមិនឆ្លើយតប ខ្លួនក៏បានច្របាច់មាត់របស់ឈ្មោះ [redacted] ណារិន ហៅ រ៉ូ ហើយគេងាកក្បាលចេញបណ្តាលឲ្យប៉ះក្រចករលាត់ក្រោមថ្កាល់បន្តិច។ ចំពោះទាក់ទងនឹងការចោទប្រកាន់ថា ខ្លួនមិនដែលជេរប្រមាថលើឈ្មោះ [redacted] ណំ ទេ តែគាត់ធ្លាប់ជេរប្រមាថមកលើខ្លួនម្តង ដោយគាត់ធ្លាប់ជេរខ្លួនថា មីសំផឹង តែខ្លួនមិនបានតបតនោះទេ គ្រាន់តែសួរថា ហេតុអីបានជេរខ្លួន។ ចំពោះការផិតក្បត់ គឺខ្លួនមិនបានប្រព្រឹត្តនោះទេ គ្រាន់តែធ្លាប់មានបងប្រុសឈ្មោះ សិទ្ធិ មកពីក្រៅប្រទេសមកលេង និងស្នាក់នៅផ្ទះចំនួន ០១សប្តាហ៍ តែពេលនោះខ្លួនពុំមានទំនាក់ទំនងអ្វីនឹងគ្នានោះទេ។ ហើយខ្លួន និងអតីតប្តីរបស់ខ្លួនពុំមានសំបុត្រអាពាហ៍ពិពាហ៍នោះទេ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុយនណារី បានឆ្លើយថា ឈ្មោះ [redacted] សុជាតិ តែងប្រើអំពើហិង្សាលើកូនៗ និងបានជេរប្រមាថទៅលើឈ្មោះ [redacted] ណំ ហើយបានរួមសេវនកិច្ចជាមួយឈ្មោះ សិទ្ធិ ក្នុងអំឡុងពេលខ្លួនទៅធ្វើការនៅប្រទេសកូរ៉េ។



Scanned with CamScanner

៤-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណំា បានបញ្ជាក់ថា ឈ្មោះ [redacted] សុជាតិ មិនដែលជេរប្រមាថមកលើខ្លួននោះទេ គ្រាន់តែធ្លាប់ឈ្លោះពាក្យសម្ដីគ្នាតែប៉ុណ្ណោះ។

៥-នៅពេលសវនាការ តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ ដោយបានបញ្ជាក់អំពីភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពីបទ **ហិង្សាដោយចេតនា ជេរប្រមាថជាសាធារណៈ និងអំពើផិត** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្ដន្ទាទោសតាមមាត្រា ២១៧, ៣០៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧, ១០ នៃច្បាប់ស្ដីពីឯកពន្ធភាព។

៦-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ បានឆ្លើយថា ខ្លួនបានច្របាច់មាត់របស់ឈ្មោះ [redacted] ណារិន ហៅ រ៉ូ ហើយឈ្មោះ [redacted] ណារិន ហៅ រ៉ូ ងាកក្បាលចេញបណ្ដាលឲ្យប៉ះក្រចករលាត់ក្រោមថ្គាល់បន្តិច មានភាពស៊ីសង្វាក់នឹងចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីនានា បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពិតជាបានប្រព្រឹត្តអំពើហិង្សាលើឈ្មោះ [redacted] ណារិន ហៅ រ៉ូ ពិតប្រាកដមែន។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ គឺជាបទល្មើស **ហិង្សាដោយចេតនា** បទល្មើសដែលបញ្ញត្តិ និងផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៨-ពេលប្រព្រឹត្តបទល្មើសជនជាប់ចោទ មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើល្មើសច្បាប់ដែលខ្លួនបានប្រព្រឹត្ត ហើយអំពើនេះបានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសណ្ដាប់ធ្នាប់សង្គម រូបរាងកាយរបស់បុគ្គលឯកជន។

៩-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្ដន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

១០-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណំា បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុជាតិ មិនបានជេរប្រមាថមកលើខ្លួនទេ។ ដូចនេះ ពុំភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពីបទ **ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្ដន្ទាទោសតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការសម្រេចឲ្យរួចផុតពីបទចោទ។

១១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងឯកសារនានាក្នុងសំណុំរឿង បានបញ្ជាក់ថា ពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សុជាតិ និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុយនណារី បានរៀបការជាមួយគ្នាត្រឹមត្រូវដោយចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ដូចនេះពុំមានធាតុផ្សំបទល្មើស ផិត គ្រប់គ្រាន់ គប្បីតុលាការសម្រេចឲ្យរួចផុតពីបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ពីបទល្មើស **អំពើផិត** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្ដន្ទាទោសតាមមាត្រា ៧, ១០ នៃច្បាប់ស្ដីពីឯកពន្ធភាព។

## ហេតុដូច្នេះសម្រេច

១-ឲ្យរួចផុតពីបទចោទលើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ភេទស្រី អាយុ៣៤ឆ្នាំ ពីបទ **អំពើផិត និងបទជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិតាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៧, ១០ នៃច្បាប់ស្ដីពីឯកពន្ធភាព។

២-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុជាតិ ភេទស្រី អាយុ៣៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំនិង០៦ខែ (មួយឆ្នាំនិងប្រាំមួយខែ) តែទោសនេះអនុវត្តល្បូរធម្មតា ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្ត

នៅចំណុចភូមិឡ ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីខែមករា ឆ្នាំ២០១៧ បទល្មើសដែលបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ហើយប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០។

-បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៣រោច ខែបុស្ស ឆ្នាំច ឯកស័ក ព.ស ២៥៦៣

ធ្វើនៅកំពង់ស្ពឺ ថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner